កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ
របៀបវារៈទី១

# យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ (យ.ជ.គ.ស) ការធានាឲ្យបានការអនុវត្តប្រកបដោយប្រសិទ្ធភាព

ដោយ

## ងី ច័ន្ទ្រផល

រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

ថ្ងៃពុធ ទី២០ ខែមេសា ឆ្នាំ២០១១
វិមានរាជរដ្ឋាភិបាល រាជធានីភ្នំពេញ
៣០៤

*ឯកឧត្តមប្រធានអង្គប្រជុំជាទីគោរព*
*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ជាទីរាប់អាន*

១. តាងនាមឲ្យឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ខ្ញុំមានកិត្តិយសបំផុតដើម្បីបង្ហាញជូនអង្គប្រជុំនាថ្ងៃនេះ នូវផែនទីគោចរសម្រាប់ការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ (យ.ជ.គ.ស)។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសំដែងនូវគារវកិច្ចនិងសេចក្តីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំនិងមន្ត្រីបច្ចេកទេសនៃរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ ដែលបានចូលរួមនិងគាំទ្រយ៉ាងសកម្ម ដល់ការធ្វើការវិភាគវិនិច្ឆ័យលើសំណាញ់សុវត្ថិភាពសង្គមដែលមានស្រាប់នៅកម្ពុជា និងការរៀបចំបង្កើតឡើងនូវឯកសារយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ដែលមានប្រសិទ្ធភាព សក្តិសិទ្ធ ស៊ីជម្រៅគ្រប់ជ្រុងជ្រោយ និងដែលអាចទទួលអនុវត្តបាន។

## សាវតារ

២. នៅក្រោយពេលនៃកលិយុគសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលនាឆ្នាំ ២០០៨ មូលបទសម្រាប់ការអភិវឌ្ឍបានផ្លាស់ប្តូររូបរាង ហើយកាតព្វកិច្ចនិងសេចក្តីតាំងចិត្តរបស់បណ្តាប្រទេសជឿនលឿននិងប្រទេសកំពុងអភិវឌ្ឍន៍ក៏បាន

ឆ្លើយតបយ៉ាងវិជ្ជមាន។ ក្នុងភាពជាប្រទេសកំពុងអភិវឌ្ឍន៍មួយ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសកម្មភាពយ៉ាងជាក់ច្បាស់ ក្នុងការឆ្លើយតបទៅនឹងកលិយុគ ក៏ដូចជាការបោះជំហានឈានមុខ ក្នុងការដោះស្រាយសម្រាលបន្ទុកនៃហានិភ័យនិងភាពមិនប្រាកដប្រជាមួយចំនួន។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ ត្រូវបានធ្វើបច្ចុប្បន្នកម្មដើម្បីបញ្ជាក់សាជាថ្មីនូវការយកចិត្តទុកដាក់ទៅលើយុទ្ធសាស្រ្តកំណើន និងទំនាក់ទំនងរវាងកំណើននិងការកាត់បន្ថយភាពក្រីក្រ។ **ការពង្រីកវិសាលភាពនៃការគាំពារសង្គម** នឹងចូលរួមដល់ការកាត់បន្ថយភាពក្រីក្រពុំរ៉ៃ ការជួយជនក្រីក្រក្នុងការសម្របខ្លួនទៅ នឹងវិបត្តិ ការបង្កើនមូលធនមនុស្ស ការលើកកម្ពស់ផលិតភាព និងការរក្សាកំណើនសេដ្ឋកិច្ចប្រកប ដោយនិរន្តរភាព។

៣. ឆ្លងកាត់រយៈពេលពីរឆ្នាំនៃដំណើរការចូលរួមនិងពិគ្រោះយោបល់យ៉ាងយ៉ិតយ៉ូន់ **យុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងងាយរងគ្រោះ** (យ.ជ.គ.ស) បានទទួលការអនុម័តពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១១។ ឯកសារនេះ ត្រូវបានរៀបចំឡើងក្នុងបរិបទនៃ គោលដៅអភិវឌ្ឍន៍សហស្សវត្សន៍កម្ពុជា ហើយដែលនឹងត្រូវសម្រេចបាន តាមរយៈផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (បច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣)។ ឯកសារនេះក៏ជាលទ្ធផលនៃសេចក្តីប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងដោយមានការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍ ហើយដែលត្រូវបានមើលឃើញថាជាគោលនយោបាយរយៈពេលយូរ ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព សម្រាប់បនុស្សគ្រប់គ្នា។

៤. **ការគាំពារសង្គមពុំមែនជាការចំណាយ ពុំមែនជាប្រតិបត្តិការសង្គ្រោះបន្ទាន់ ហើយក៏មិនមែនជាកញ្ចប់ថវិកាសម្រាប់ស្រោចស្រង់ជនក្រីក្រនិងជនងាយរងគ្រោះពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចដែរ។** ការគាំពារសង្គម ជាការវិនិយោគសម្រាប់អភិវឌ្ឍន៍របស់ប្រទេសជាតិ ដែលផ្តល់មកវិញនូវការកាត់បន្ថយភាពក្រីក្រ ការបង្កើនតម្រូវការដែលអាចបកស្រាយបានថាជាការពង្រីកទីផ្សារ និងកម្លាំងពលកម្មដែលកាន់តែមានផលិតភាពខ្ពស់ មានការសិក្សាអប់រំខ្ពស់ និងមានសុខភាពប្រសើរ។

## ការអនុវត្តយុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងងាយរងគ្រោះ

៥. **ការអនុវត្តយុទ្ធសាស្រ្តនេះ នឹងទាមទារឲ្យពង្រីកបន្ថែមនូវអន្តរាគមន៍ដែលមានស្រាប់ ការរៀបចំស្ថាប័ន និងការបង្កើតឡើងនូវកម្មវិធីថ្មីដើម្បីគ្រប់ដណ្តប់លើចន្លោះប្រហោងដែលមានស្រាប់។** ការគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ គឺជាការងារអន្តរវិស័យ

ហើយទាមទារការសម្របសម្រួលប្រកបដោយ ប្រសិទ្ធភាព និងកិច្ចសហប្រតិបត្តិការរវាងក្រសួងស្ថាប័នជំនាញ ក៏ដូចជាទំនាក់ទំនងយ៉ាងសកម្ម ជាមួយបណ្តាដៃគូអភិវឌ្ឍនិងអង្គការសង្គមស៊ីវិលដែលគាំទ្រលើវិស័យនេះ។ ដោយសារកម្មវិធីភាគច្រើនក្នុងការគាំពារសង្គម មានធម្មជាតិអន្តរវិស័យ ដូច្នេះហើយទើបប្រការនេះទាមទារនូវការសម្របសម្រួលរវាងក្រសួងជំនាញ ដើម្បីជៀសវាងការត្រួតជាន់គ្នាជាលក្ខណៈវិស័យការងារ ឬតំបន់ ភូមិសាស្រ្ត ក៏ដូចជាដើម្បីធ្វើសុខដុមនីយកម្មលើនីតិវិធីក្នុងការអនុវត្ត និងការសម្របសម្រួលលើការប្រើប្រាស់ធនធានដែលមានពីថវិកាជាតិនិងដៃគូអភិវឌ្ឍ។

៦. **ជំហានបន្ទាប់ក្នុងការរៀបចំសម្រាប់ការអនុវត្តយុទ្ធសាស្រ្តនេះ គឺការកំណត់ឲ្យឃើញនិងឲ្យបានច្បាស់លាស់នូវសកម្មភាពដែលនឹងត្រូវអនុវត្តក្នុងដំណាក់កាលខ្លី**

ដើម្បីរក្សាស្ថេរភាពនៃវឌ្ឍនភាពការងារដែលសម្រេចបានក្នុងមួយឆ្នាំកន្លងមក លើអណត្តិការងារការគាំពារសង្គម។ **ក្នុងដំណាក់កាលខ្លីនិងមធ្យម** យុទ្ធសាស្រ្តជាតិគាំពារសង្គមនឹងផ្តល់អាទិភាពលើការរៀបចំបង្កើតសំណាញ់សុវត្ថិភាពសង្គមដែលមានប្រសិទ្ធភាពនិងនិរន្តរភាព ដែលផ្តោតគោលដៅលើជនក្រីក្រនិងជនងាយរងគ្រោះ ជាមួយនិងសេវាកម្មសុខុមាលភាពសង្គមបំពេញ បន្ថែមសម្រាប់ក្រុមជនងាយរងគ្រោះពិសេស។ **ក្នុងដំណាក់កាលវែង** យុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ បានកំណត់ក្របខណ្ឌការគាំពារសង្គមដែលមាននិរន្តរភាពនិងស៊ីជម្រៅ សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប ដោយសម្រេចបាននូវវិសាលភាពគ្របដណ្តប់សកល លើហានិភ័យនិងភាពងាយរងគ្រោះ ជាមួយនិងកញ្ចប់ជំនួយឧបត្ថម្ភនិងសេវាកម្មមូលដ្ឋាន ដែលមានលក្ខណៈសមរម្យទៅតាមការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ប្រការនេះរួមមានទាំងយន្តការរបបសន្តិសុខសង្គម ដោយមានភាគទានសម្រាប់វិស័យផ្លូវការ និងការធ្វើឲ្យកាន់តែប្រសើរឡើងនូវសំណាញ់សុវត្ថិភាពសង្គមសម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ **ដើម្បីឈានឆ្ពោះទៅកាន់ទស្សនៈវិស័យវែងឆ្ងាយនេះ គេត្រូវផ្តោតការយកចិត្តទុកដាក់លើចំនុចមួយចំនួនដូចខាងក្រោម ៖**

- ដោយសារយុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជន ត្រូវបានរៀបចំឡើងក្នុងលក្ខណៈជាយុទ្ធសាស្រ្តសម្របសម្រួលហើយមិនមែនជាយុទ្ធសាស្រ្តតាមវិស័យ ដូច្នេះផែនការសកម្មភាពដែលមានលក្ខណៈស៊ីជម្រៅ ព្រមទាំងការពិភាក្សាសកម្មជាមួយក្រសួងជំនាញ នឹងត្រូវបន្តធ្វើ
- ដើម្បីផ្លាស់ប្តូរពីសំណាញ់សុវត្ថិភាពសង្គមឬប្រព័ន្ធបញ្ចុកចំណីដល់មាត់ ឲ្យទៅជាប្រព័ន្ធរបបសន្តិសុខសង្គមដែលមានលក្ខណៈស៊ីជម្រៅនិងទូលំទូលាយ ព្រះរាជាណាចក្រកម្ពុជានឹងត្រូវមានការប្រុងប្រយ័ត្នពីបញ្ហាភាពប្រេះឆាក្នុងសង្គម ដែលបណ្តាលមកពីការផ្តោតការយកចិត្ត

ទុកដាក់តែទៅលើក្រុមពិសេសណាមួយក្នុងសង្គម។ ប្រការនេះទាមទារឲ្យមានការធានានូវកំណើនសម្រាប់មនុស្សគ្រប់គ្នា។

- ការសម្រេចបាននូវគោលដៅរបស់យុទ្ធសាស្ត្រ ទាមទារឲ្យមានការបញ្ចូលគ្នានៃកម្មវិធីដែលគ្របដណ្តប់លើភាពក្រីក្ររ៉ាំរ៉ៃ និងភាពក្រីក្រដែលទើបនឹងកើតឡើង ក៏ដូចជាភាពអត់ឃ្លាន ព្រមទាំងជួយលើកកម្ពស់មូលធនមនុស្ស
- ការដោះស្រាយប្រភពសំខាន់ៗនៃភាពងាយរងគ្រោះនឹងជាសកម្មភាពអាទិភាព ក្នុងពេលជាមួយគ្នានេះ គឺការកសាងមូលដ្ឋានសំណាញ់សុវត្ថិភាពសង្គមដែលមានប្រសិទ្ធភាពមួយ
- ការផ្សារភ្ជាប់ប្រភពសំខាន់នៃភាពងាយរងគ្រោះទៅនឹងកម្មវិធីដែលមានស្រាប់ ទាមទារនូវពង្រឹងការសម្របសម្រួល ការពង្រីក និងការធ្វើសុខដុមនីយកម្មលើអន្តរាគមន៍ដែលមានស្រាប់[1]
- នៅក្នុងការពង្រីកវិសាលភាពនៃអន្តរាគមន៍មួយចំនួន ប្រការសំខាន់គឺការធ្វើសុខដុមនីយកម្មលើដំណើរការ និងការធានាហិរញ្ញប្បទានឲ្យបានទៀងទាត់ ដើម្បីធានានិរន្តរភាពក្នុងរយៈពេលមធ្យម។ បន្ថែមលើនេះ វិសាលភាពនៃកម្មវិធីដែលមានស្រាប់ នឹងត្រូវវាយតម្លៃជាថ្មីម្តងទៀត ហើយត្រូវកែតម្រូវជាមួយនឹងកម្រិតនៃភាពក្រីក្រនិងភាពងាយរងគ្រោះ នៅថ្នាក់ខេត្តនិងថ្នាក់ស្រុក
- ចន្លោះប្រហោងនៃការគាំពារសង្គមសម្រាប់ជនក្រីក្រនិងងាយរងគ្រោះ នឹងត្រូវដោះស្រាយដោយកម្មវិធីថ្មី ដែលនឹងជួយសម្រាលដល់បន្ទុកនៃភាពក្រីក្ររ៉ាំរ៉ៃ និងការបង្កើនមូលធនមនុស្ស[2]

## ការបង្កើតបរិស្ថានសម្រាប់ការសម្របសម្រួលយុទ្ធសាស្ត្រជាតិគាំពារសង្គម

៧. ការរៀបចំស្ថាប័ននិងការបង្កើតនីតិវិធីសម្រាប់ការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម ប្រកបដោយប្រសិទ្ធភាពនិងភាពសក្តិសិទ្ធ កំពុងស្ថិតក្នុងដំណើរការនៅឡើយ ហើយគោលការណ៍ណែនាំនិងជម្រើសជាអាទិភាពមួយចំនួន បានចែងរួចជាស្រេចហើយនៅក្នុងឯកសារយុទ្ធសាស្ត្រ ប៉ុន្តែចំណុចទាំងនេះនៅទាមទារឲ្យមានការបង្ហាញឲ្យបានពិស្តារនៅអំឡុងឆ្នាំដំបូងនៃការអនុវត្ត ដើម្បី បង្កើតឡើងនូវបរិស្ថានមួយសម្រាប់ការសម្របសម្រួលយុទ្ធសាស្ត្រ។

---

[1] មូលនិធិសមធម៌ កម្មវិធីអាហារូបករណ៍ និងកម្មវិធីសំណង់សាធារណៈ សុទ្ធសឹងតែជាប្រភេទកម្មវិធីដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយភាពងាយរងគ្រោះចម្បងៗដែលជួបប្រទះដោយជនក្រីក្រ។ ទោះជាយ៉ាងណា កម្មវិធីទាំងនេះមួយចំនួនដូចជាកម្មវិធីសំណង់សាធារណៈ មាននិន្នាការ ទៅរកការអនុវត្តដោយដៃគូអភិវឌ្ឍចម្រុះ ហើយមានលក្ខណៈជាបណ្តោះអាសន្នដោយពុំមានការសម្របសម្រួល ហើយនិរន្តរភាពក្នុងដំណាក់កាលមធ្យមរបស់កម្មវិធីទាំងនេះ នៅស្ថិតក្នុងភាពស្រពិចស្រពិល។

[2] អន្តរាគមន៍សាកល្បងថ្មីៗ រួមមានកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដោយផ្តោតលើលទ្ធផលនៃរបាហារូបត្ថម្ភមាតានិងកុមារ សុខភាព និងការអប់រំ និងការកាត់បន្ថយពលកម្មកុមារ ក៏ដូចជាកម្មវិធីផ្តល់ឱកាសថ្មីដែលបង្កើនជំនាញសម្រាប់យុវជនដែលពុំបានចូលរៀន និងការផ្តល់ការគាំទ្រដល់ពលករជាកុមារឲ្យចូលប្រព័ន្ធអប់រំសាជាថ្មី។

៧. ដើម្បីជៀសវាងការគ្របដណ្តប់និងត្រួតជាន់គ្នា លើក្រុមអ្នកទទួលផលពិសេសណាមួយក្នុងសង្គមក្នុងពេលដែលក្រុមជនផ្សេងទៀតពុំបានទទួលការគ្របដណ្តប់នោះ **កិច្ចខិតខំសម្របសម្រួល** រវាង កម្មវិធីដែលមានលក្ខណៈស្រដៀងគ្នា ក៏ដូចជារវាងអន្តរាគមន៍ផ្សេងទៀត គឺជាប្រការចាំបាច់។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បានទទួលអាណត្តិការងារពីរាជរដ្ឋាភិបាល សម្រាប់ការសម្របសម្រួលទូទៅលើយុទ្ធសាស្ត្រជាតិគាំពារសង្គម ហើយនឹងត្រូវអនុវត្តសកម្មភាពយ៉ាងជិតស្និទ្ធជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រសួងផែនការ និងក្រសួងមហាផ្ទៃ។ រចនាសម្ព័ន្ធ និងយន្តការសមរម្យ ដើម្បីធានាការសម្របសម្រួលនិងការពិនិត្យតាមដានលើយុទ្ធសាស្ត្រជាតិគាំពារសង្គម នឹងត្រូវកំណត់ឡើង។ **ការអនុវត្តកម្មវិធីគាំពារសង្គមនឹងជាទំនួលខុសត្រូវទាំងស្រុងរបស់ក្រសួងជំនាញៗ** ដើម្បីឲ្យការអនុវត្តអាចប្រព្រឹត្តទៅបានដោយជោគជ័យ ការចូលរួមដោយសកម្មពីរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ (ក្រុមប្រឹក្សាខេត្ត ស្រុក និងឃុំ) នឹងជាប្រការចាំបាច់[3]។ **អង្គភាពសម្របសម្រួលការគាំពារសង្គម** ត្រូវបានបង្កើតឡើងដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រសម្រាប់តួនាទីសម្របសម្រួល។ ជាលក្ខណៈមូលដ្ឋាន អង្គភាពនេះនឹងដឹកនាំការគាំទ្រគោលនយោបាយគាំពារសង្គម ការវិភាគផែនការថវិកាសម្រាប់ការអនុវត្តយុទ្ធសាស្ត្រគាំពារសង្គម ភាពជាដៃគូនិងទំនាក់ទំនង ការពិនិត្យតាមដាននិងវាយតម្លៃ និងការគ្រប់គ្រងពត៌មាន។

៨. **ការពិនិត្យតាមដាននិងវាយតម្លៃ** លើអន្តរាគមន៍និងកម្មវិធី និងយុទ្ធសាស្ត្រទាំងមូល នឹងជាតម្រូវការចាំបាច់ សម្រាប់ការពិភាក្សាសកម្មលើការគាំពារសង្គមនៅកម្ពុជា។ យុទ្ធសាស្ត្រជាតិគាំពារសង្គមជាឯកសាររស់មួយ ហើយមានលទ្ធភាពសម្របទៅតាមបរិស្ថានដែលមានការប្រែប្រួលនិងប្រភពនៃភាពងាយរងគ្រោះ ក៏ដូចជាសេចក្តីត្រូវការក្នុងការពិចារណាលើមេរៀនជាលក្ខណៈប្រព័ន្ធ ដែលដកស្រង់ចេញក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធីនិងអន្តរាគមន៍។ ដូច្នេះ **ម៉ាទ្រីសនៃលទ្ធផលសម្រាប់យុទ្ធសាស្ត្រជាតិគាំពារសង្គមនឹងត្រូវបង្កើតឡើងដោយបង្ហាញពីសូចនាករនៃលទ្ធផលគន្លឹះ** សម្រាប់គោលដៅទាំង៥។ បន្ថែមលើនេះទៀត យន្តការមួយដើម្បីពិនិត្យតាមដានការប្រើប្រាស់ធនធានដែលមាន នឹងត្រូវរៀបចំឡើងដើម្បីធានាប្រសិទ្ធភាពនៃការចំណាយ និងតម្លាភាព។ ការតាមដានវាយតម្លៃលើអន្តរាគមន៍និងកម្មវិធីពិសេសនានា នឹងត្រូវអនុវត្តដោយក្រសួងជំនាញ

[3] Therefore the RGC will establish provincial and district committees (with due attention to whether SP could be linked to existing sub-committees or whether new ones need to be created) to oversee social protection activities at their level and to coordinate implementing departments of ministries and involved civil society organizations. At the local level the commune council (including Consultative Committee on Children and Women) will oversee targeting and implementation of social protection activities.

ប៉ុន្តែក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ក្នុងនាមជាស្ថាប័នសម្របសម្រួលលើយុទ្ធសាស្ត្រ នឹងដើរតួនាទីពិនិត្យទូទៅ និងផ្តល់ការប្រឹក្សាបច្ចេកទេសសម្រាប់សកម្មភាពពិនិត្យតាមដាននិងវាយតម្លៃលើការគាំពារសង្គម។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ក៏នឹងរៀបចំការត្រួតពិនិត្យឯករាជ្យលើយុទ្ធសាស្ត្រជាតិគាំពារសង្គម ដើម្បីគាំទ្រដល់ការពិភាក្សាដោយមានពត៌មានពិតប្រាកដលើការសម្របសម្រួលទូទៅ ការរៀបចំយុទ្ធសាស្ត្រនៅពេលបន្តទៀត។

៩. **ការគ្រប់គ្រងពត៌មាននិងចំណេះដឹង** ស្តីពីការគាំពារសង្គម គឺជាមជ្ឈមណ្ឌលនៃការទ្រទ្រង់ដល់ការសម្របសម្រួលដែលមានប្រសិទ្ធភាព។ សមត្ថភាពសម្រាប់ការគ្រប់គ្រងពត៌មាននិងចំណេះដឹង នឹងត្រូវពង្រឹងឲ្យកាន់តែរឹងមាំ ដើម្បីធានាដល់ការប្រមូល ផលិត និងចែកចាយពត៌មានបច្ចុប្បន្នភាព រវាងស្ថាប័នពាក់ព័ន្ធ[4]

១០. **ការកសាងសមត្ថភាព** លើការរៀបចំនិងការអនុវត្តកម្មវិធីណាមួយ ក៏ដូចជាការសម្របសម្រួល និងការពិនិត្យតាមដានលើយុទ្ធសាស្ត្រទាំងមូល នឹងត្រូវផ្តល់ជូនស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្រុមគ្រូបង្គោលដែលមានសមាសភាពមកពីក្រសួងស្ថាប័នពាក់ព័ន្ធ នឹងត្រូវបង្កើតឡើងដើម្បីធានាឲ្យបានលើការយល់ដឹងនិងការអនុវត្ត ហើយមន្ត្រីបង្គោលនៅថ្នាក់ខេត្ត និងថ្នាក់ស្រុកនឹងត្រូវបណ្តុះបណ្តាលក្នុង **លក្ខណៈជាប្រព័ន្ធនៃការបង្រៀនបន្តគ្នា** ដើម្បីបង្រៀនបន្តដល់ក្រុមប្រឹក្សាឃុំ។ ការបណ្តុះបណ្តាលកសាងសមត្ថភាពនិងការរៀបចំស្ថាប័នជាបន្ត នឹងជាប្រការចាំបាច់ដើម្បីសម្រេចបាននូវគោលដៅនេះក្នុងដំណាក់កាលវែង។ ទោះជាយ៉ាងណា សកម្មភាពផ្តួចផ្តើមដំបូងទាំងនេះនឹងផ្តល់លទ្ធភាពក្នុងការចាប់ផ្តើមអនុវត្តកម្មវិធីគាំពារសង្គមដែលមានការសម្របសម្រួល ក្នុងដំណាក់កាលមធ្យម (ឧទាហរណ៍ ឆ្នាំ២០១៣-២០១៥ ដែលជាផ្នែកចុងក្រោយនៃយុទ្ធសាស្ត្រ)។

១១. **យន្តការកំណត់ក្រុមគោលដៅដែលសមរម្យ ជាកត្តាចាំបាច់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គមប្រកបដោយប្រសិទ្ធភាពលើការចំណាយ។** អភិក្រមចម្រុះមួយសម្រាប់ការជ្រើសរើសអ្នកទទួលផលពីការអន្តរាគមនិងកម្មវិធី ដែលរួមបញ្ចូលនូវការកំណត់អត្តសញ្ញាណដោយអ្នកទទួលផលខ្លួនឯង ការកំណត់អត្តសញ្ញាណអ្នកទទួលផលតាមលក្ខណៈភូមិសាស្ត្រ ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ

[4] Campaigns (IEC) will create awareness about social protection and respective programs and information on the outcome of the strategy and its programs will be shared through national and regional fora and thematic workshops. Discussions on social protection organized at district and commune level will ensure a feed-back mechanism to the province and national policy level. CARD will develop and continuously update a web-based information and knowledge-platform on social protection.

នឹងប្រើប្រាស់ដើម្បីជ្រើសរើសអ្នកទទួលផលឲ្យបានសមរម្យបំផុត។ អភិក្រមដែលមានសុខដុមនីយភាពមួយ សម្រាប់ការធ្វើបុរេអត្តសញ្ញាណកម្មគ្រួសារក្រីក្រដោយផ្អែកលើបទដ្ឋាននីតិវិធីមួយចំនួន និងគ្រប់លក្ខខណ្ឌសម្រាប់ការឧបត្ថម្ភសង្គមនិងការលើកលែងថ្លៃគ្រប់ប្រភេទ ត្រូវបានបង្កើតឡើងរួចហើយនាពេលថ្មីៗនេះនៅកម្ពុជា។ "កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ" នាពេលបច្ចុប្បន្ននេះ បានគ្របដណ្តប់ភូមិចំនួនប្រមាណ៧១០០ក្នុងខេត្តចំនួន១៧ ហើយការពង្រីកឲ្យបានគ្រប់ភូមិនឹងមានផែនការធ្វើឡើងក្នុងឆ្នាំ២០១១។ អភិក្រមដែលបានបង្កើតឡើងដោយក្រសួងផែនការដោយមានការពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធ មានប្រសិទ្ធភាពខ្ពស់ និងមានអត្រាកំហុសឆ្គងទាបនៃការរាប់បញ្ចូល ឬពុំបានរាប់បញ្ចូលគ្រួសារក្រីក្រ។ វិធីសាស្ត្រនេះត្រូវបានទទួលស្គាល់ដោយសហគមន៍ភាគច្រើន និងកាន់តែទទួលបានការប្រើប្រាស់កាន់តែច្រើននៅក្នុងការកំណត់អត្តសញ្ញាណអ្នកទទួលផល សម្រាប់កម្មវិធីសំណាញ់សុវត្ថិភាពសង្គម។ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នឹងក្លាយជាឧបករណ៍គន្លឹះមួយសម្រាប់ការកំណត់គោលដៅកម្រិតគ្រួសារ ហើយអាចនឹងត្រូវប្រើប្រាស់រួមបញ្ចូលជាមួយយន្តការមួយចំនួនដែលត្រូវធ្វើក្រោយពេលកំណត់អត្តសញ្ញាណ ដើម្បីត្រួតពិនិត្យនិង កែតម្រូវលើការកំណត់គោលដៅកម្រិតគ្រួសារសម្រាប់អន្តរាគមន៍មួយចំនួន។ ការពង្រីកវិសាលភាពនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រទៅកាន់គ្រប់ភូមិទាំងអស់នៅតំបន់ជនបទ ដោយមានការធ្វើបច្ចុប្បន្នកម្មជារៀងរាល់ពីរឆ្នាំលើបញ្ជីភាពក្រីក្រ ការវាយតម្លៃលើសុក្រឹត្យភាពនៃប្រព័ន្ធក៏ដូចជាការរៀបចំបង្កើតយន្តការកំណត់គោលដៅសម្រាប់តំបន់ទីប្រជុំជន នឹងជាផ្នែកមួយនៃផែនការ សកម្មភាពអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម។

១២. **ការកែតម្រូវនិងការធ្វើសុខដុមនីយកម្ម** ៖ ការអនុវត្តកម្មវិធីគាំពារសង្គមនឹងជាការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នពាក់ព័ន្ធនិងស្ថាប័នថ្នាក់ក្រោមជាតិ ដោយផ្អែកលើគោលការណ៍ណែនាំរួមគ្នាមួយចំនួន។ ដើម្បីឲ្យការអនុវត្តអាចប្រព្រឹត្តទៅបានដោយជោគជ័យ ការចូលរួមពីរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ (ក្រុមប្រឹក្សាខេត្ត ស្រុក និងឃុំ) នឹងជាប្រការចាំបាច់។ រាជរដ្ឋាភិបាលកម្ពុជានឹងធានាឲ្យមានការសម្របសម្រួលសកម្មភាពគាំពារសង្គមប្រកបដោយប្រសិទ្ធភាព រវាងមន្ទីររបស់ក្រសួងនានា និងសង្គមស៊ីវិលដែលកំពុងអនុវត្តការងារនៅថ្នាក់ខេត្តនិងស្រុក។ ក្រុមប្រឹក្សាឃុំ សង្កាត់ (រួមទាំង គណៈកម្មការផ្តល់សេវាប្រឹក្សាសម្រាប់ស្ត្រី និងកុមារ) នឹងត្រួតពិនិត្យការកំណត់គោលដៅ និងការអនុវត្តសកម្មភាពគាំពារសង្គមនៅថ្នាក់មូលដ្ឋាន។ ក្នុងបរិបទនេះ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ កសិកម្មនិងជនបទនឹងធ្វើការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍ ដើម្បីសម្រេចបាននូវសុខដុមនីយ ភាព

និងភាពផ្សារភ្ជាប់គ្នានៃគោលនយោបាយ រវាងដៃគូអភិវឌ្ឍនិងរាជរដ្ឋាភិបាល ក្នុងការរៀបចំកម្មវិធីជំនួយសម្រាប់ប្រទេស នៅពេលប្រាំឆ្នាំខាងមុខ ឬពេលបន្ទាប់ទៀត។

១៣. **ប្រការចាំបាច់មួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការឈានជំហានទៅមុខជាបន្តទៀតលើរបៀបវារៈការងារនៃការគាំពារសង្គម គឺការរក្សាសុទិដ្ឋិភាពនៃជំនួយរបស់ដៃគូអភិវឌ្ឍ។** ការចូលរួមគ្នាលើហិរញ្ញប្បទានសម្រាប់ជំនាញការបច្ចេកទេស អាចជាវិធីសាស្រ្តមួយ សម្រាប់គាំទ្រដល់ការកសាងសមត្ថភាព ហើយដែលការទទួលខុសត្រូវលើផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុជាក់លាក់មួយចំនួន អាចនឹងកាន់តែមានប្រសិទ្ធភាពសម្រាប់ការរៀបចំកម្មវិធីមួយចំនួនដោយផ្អែកលើលក្ខណៈសម្បត្តិប្រៀបធៀប។ ទោះជាយ៉ាងណា កិច្ចសហការនិងការធ្វើប្រតិកម្មតបរវាងក្រុមដៃគូអភិវឌ្ឍទូលាយមួយ អាចនឹងត្រូវធ្វើឡើងជាប្រចាំ ក្នុងបរិបទនៃក្រុមការងារអចិន្ត្រៃយ៍មួយ។ ការផ្តល់ហិរញ្ញប្បទានអាចនឹងមានការវិវត្តទៅកាន់បែបផែនរួមគ្នាមួយ ដូចជាអភិក្រមទូទាំងវិស័យ ឬមូលដ្ឋានកម្មវិធី ដែលនឹងបង្ការការបែកខ្ញែកគ្នា និងជំនួយដល់ការសម្របសម្រួលលើអន្តរាគមន៍គាំពារសង្គម។ ខ្ញុំសូមស្វាគមន៍ ដល់ការបន្តការគាំទ្ររបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី។

សូមអរគុណ